អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# គូគូ កូនដំរី



Written by Sem Rasin

Illustration by Sem Rasin



កាលពីព្រេងនាយ មានកូនដំរីតូចមួយក្បាលឈ្មោះថា តូតូ។ តូតូមានត្រចៀកធំៗ
និងប្រមោយវែងគួរឱ្យស្រឡាញ់ ហើយតូតូរស់នៅក្នុងព្រៃជ្រៅជាមួយម្ដាយរបស់វា។





ថ្ងៃមួយ តូតូបានសួរម្ដាយវាថា «ម៉ាក់ៗ! តើនៅជុំវិញព្រៃដែលយើងរស់នៅមានអ្វីខ្លះ?» ម្ដាយតូតូញញឹមហើយឆ្លើយថា «នៅជុំវិញនេះ មានពិភពលោកដ៏ធំទូលាយ តែកូនត្រូវប្រយ័ត្ន កុំដើរឆ្ងាយពីម៉ាក់ឱ្យសោះណា!»



 

ថ្ងៃមួយ ម្ដាយរបស់តូតូកំពុងដេកលង់លក់។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញត្រឹមខ្សែបន្ទាត់]

តូតូបានឃើញមេអំបៅពណ៌លឿងមួយក្បាលហើរកាត់

តូតូក៏រត់ដេញតាមមេអំបៅនោះយ៉ាងសប្បាយរីករាយ រហូតភ្លេចខ្លួន ធ្វើឱ្យវង្វេងផ្លូវ។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញឱ្យឃើញរូបភាពពេញ១ទំព័រ]







តូតូបានជួបនឹងសត្វស្វាមួយក្បាលឈ្មោះ ទីទី។
ទីទីសួរថា «អូ! កូនដំរីតូច! តើឯងឈ្មោះអី? ហើយឯងកំពុងទៅណាហ្នឹង?»
តូតូឆ្លើយ «ខ្ញុំឈ្មោះតូតូ! ខ្ញុំកំពុងដេញតាមមេអំបៅពណ៌លឿង!
តើឯងចង់លេងជាមួយខ្ញុំទេ?»។





តូតូនិងទីទីបានលេងបិទពួនជាមួយគ្នាយ៉ាងសប្បាយរីករាយ។
តូតូប្រើប្រមោយវែងរបស់វាបាញ់ទឹកដាក់ទីទី ដូចជាការងូតទឹកផ្កាឈូកអ៊ីចឹង។





មិនយូរប៉ុន្មាន មេឃចាប់ផ្ដើមងងឹត តូតូចង់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែវារកផ្លូវមិនឃើញនោះទេ។ តូតូចាប់ផ្ដើមភ័យ ហើយនិយាយទាំងចង់យំថា «ម៉ាក់ៗ! ម៉ាក់នៅឯណា?» ទីទីនិយាយថា «កុំខ្លាចអីតូតូ! ខ្ញុំនឹងជួយឯង»។ ទីទីបានឡើងលើចុងឈើខ្ពស់បំផុតដើម្បីរកមើលម្ដាយរបស់តូតូ។





ទីទីបានឃើញព្រះអាទិត្យកំពុងរៀបលិច ហើយឃើញម្ដាយរបស់តូតូ
និងឮសំឡេងហៅ «តូតូៗ! កូននៅទីណា?»។ ទីទីស្រែក «តូតូៗ! មើលហ្ន៎»។





តូតូបានរត់ទៅរកម្ដាយរបស់វាយ៉ាងលឿន។ ម្ដាយតូតូបានយកប្រមោយឱបតូតូយ៉ាងកក់ក្ដៅ។ តូតូនិយាយថា «កូនសុំទោស ម៉ាក់ៗ! ដែលកូនមិនស្ដាប់ដំបូន្មានរបស់ម៉ាក់ កូននឹងមិនដើរចេញឆ្ងាយទៀតទេ»។





យប់នោះ តូតូបានគេងលក់យ៉ាងស្កប់ស្កល់ក្បែរជើងម្ដាយរបស់វា។ តូតូដឹងថាគ្មានកន្លែងណាដែលមានសុវត្ថិភាព និងកក់ក្ដៅជាងការនៅក្បែរម្ដាយរបស់វានោះឡើយ។






# តូតូ កូនដំរី

អ្នកនិពន្ធ៖ សែម រ៉ាស៊ីន

រូបភាពដោយ៖ សែម រ៉ាស៊ីន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary